ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

**សំណុំរឿងព្រហ្មទណ្ឌ**

លេខ:៨៧២/២៣-១១-២០០៥

**សាលដីកា**

លេខ:៤៦(ច)/២៨-៨-២០០៩

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ:០៦ក្រ ចុះថ្ងៃទី០៨-០២-១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍នាថ្ងៃទី២៨-៨-២០០៩ ដែលមានសមាសភាពដូចតទៅ :

**សមាសភាពក្រុមប្រឹក្សា**

លោក [redacted] ជាប្រធាន

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ:៨៧២ ចុះថ្ងៃទី២៣-១១-២០០៥ រវាង :

១-ជនជាប់ចោទឈ្មោះ [redacted] គត់ ហៅ ឆែម ភេទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរ មុខរបររត់ម៉ូតូឌុប កើតនៅភូមិ [redacted] ទីលំនៅសព្វថ្ងៃ [redacted] ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] ទោសពីមុនគ្មាន ។ ចាប់ខ្លួនថ្ងៃទី១៦-០២-២០០៥ ឃុំខ្លួនថ្ងៃទី២២-០២-២០០៥ (ជាអ្នកប្តឹងឧទ្ធរណ៍) ។

២-ជនជាប់ចោទឈ្មោះ [redacted] តឹក ភេទប្រុស អាយុ២១ឆ្នាំ ជាតិខ្មែរ មុខរបរនៅផ្ទះ កើតនៅភូមិ [redacted] ទីលំនៅមុនពេលចាប់ខ្លួន [redacted] ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនគ្មាន ។ ចាប់ខ្លួនថ្ងៃទី១៦-០២-២០០៥ ឃុំខ្លួនថ្ងៃទី២២-០២-២០០៥ (ជាអ្នកប្តឹងឧទ្ធរណ៍) បច្ចុប្បន្នឃុំខ្លួននៅពន្ធនាគារព្រៃសម១ ។

ត្រូវចោទពីបទ: ប្លន់ និង ប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី១៥-០២-២០០៥ តាមមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

៣-ជនជាប់ចោទឈ្មោះ [redacted] ខ្លី ភេទប្រុស អាយុ២២ឆ្នាំ ជាតិខ្មែរ មុខរបរតួកជេរម៉ូតូ កើតនៅ [redacted] ទីលំនៅសព្វថ្ងៃផ្ទះជួលលេខ [redacted] ឪពុកឈ្មោះ [redacted](ស) ម្ដាយឈ្មោះ [redacted](រ) ប្រពន្ធឈ្មោះ [redacted] មានកូន០១នាក់ ទោសពីមុនគ្មាន ។ ក្រៅឃុំ ។

មេធាវីការពារឈ្មោះ [redacted] **យ៉ារ៉ាន់**

ត្រូវចោទពីបទៈ ទទួលផលចោរកម្ម ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី១៦-០២-២០០៥ តាមមាត្រា៥១ និង ៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] **គង់** អាយុ២៤ឆ្នាំ ភេទប្រុស ជាតិខ្មែរ មុខរបរគ្រូបង្រៀន មានទីលំនៅផ្ទះលេខ២៣៤ ផ្លូវ១០៧ សង្កាត់បឹងព្រលិត ខណ្ឌ៧មករា ក្រុងភ្នំពេញ ។

តាមពាក្យបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី២៨-៦-២០០៥ របស់ឈ្មោះ [redacted] **គង់** និង [redacted] **តឹក** ប្ដឹងឧទ្ធរណ៍នឹងសាលក្រមលេខៈ៧៩(គ) ចុះថ្ងៃទី២៨-៦-២០០៥ របស់តុលាការក្រុងភ្នំពេញ លើចំណុចទី១,៣,៤,៥,៦ នៃសេចក្ដីសម្រេច ។

## រឿងហេតុមានដូចតទៅ

តាមពាក្យបណ្ដឹងចុះថ្ងៃទី១៥-០២-២០០៥ របស់ឈ្មោះ [redacted] **គង់** ប្ដឹងជនមិនស្គាល់មុខពីរនាក់មានអាវុធខ្លីមួយដើម ពីបទៈប្លន់ ដោយសំអាងហេតុថា កាលពីថ្ងៃទី១៥-០២-២០០៥ វេលាម៉ោង២១:១៥នាទី ខ្លួនជិះម៉ូតូឌុបមិត្តភ័ក្ត្រចេញពីផ្លូវ១០៩ បត់ចូលផ្លូវ១៦០ ឈប់មុខច្រកចូលខឿងហែម ស្រាប់តែមានជនម្នាក់ដើរមកមានកាំភ្លើងមិនស្គាល់ម៉ាក សំឡុតគំរាមខ្លួនយកទូរស័ព្ទដៃ តែយកមិនបានក៏គំរាមភ្ជង់យកម៉ូតូតែម្ដង ហើយជិះចេញទៅទិសខាងកើតបាត់ ។ ម៉ូតូនោះម៉ាកCub៩០ ពណ៌ទឹកប្រាក់ស៊េរី២០០៤ ។

-តាមចម្លើយចុះថ្ងៃទី១៥-០២-២០០៥ របស់ឈ្មោះ [redacted] **គង់** ជាជនរងគ្រោះ ឆ្លើយនៅប៉ូលីសដូចក្នុងពាក្យបណ្ដឹង ។

-តាមចម្លើយចុះថ្ងៃទី២៥-០៣-២០០៥ របស់ឈ្មោះ [redacted] **គង់** ជាជនរងគ្រោះ ឆ្លើយនៅចៅក្រមស៊ើបថាៈ នៅថ្ងៃទី១៥-០២-២០០៥ ម៉ោង៩ទៅ៩:៣០នាទី ខ្លួនជិះពីមាត់ទន្លេមកផ្ទះ មានស្រីពីរនាក់ជិះពីក្រោយ ដល់ចំណុចរោងកុនអង្គរខ្លួនឈប់ ស្រាប់តែមានជនម្នាក់ដើរពីក្រោយ មកសួររកទូរស័ព្ទពីស្រី១ជិះពីក្រោយខ្លួន ស្រី១រត់ចូលផ្លូវតូចបាត់ទៅ វាកាន់កាំភ្លើងគំរាមបាញ់ខ្លួន១ក៏ចុះពីលើម៉ូតូប្រគល់ឱ្យវា បន្ទាប់មកវាទារទូរស័ព្ទទៀត តែខ្លួនពុំព្រមឱ្យ វាក៏ជិះម៉ូតូខ្លួនចេញបាត់ទៅ ។ ខ្លួនឃើញមានគ្នាពីរនាក់ ម្នាក់អង្គុយលើម៉ូតូចម្ងាយប្រហែល២ម ម្នាក់មកប្លន់ខ្លួននោះរាងខ្ពស់ខ្មៅ សក់ខ្លី ។ ម៉ូតូខ្លួនម៉ាកCub៩០ ពណ៌ទឹកប្រាក់មានលេខតួ២៦២៨៦២៤ និង លេខម៉ាស៊ីន៣០៥០៥១៣ ទិញតម្លៃ១៧៥០ដុល្លា នៅថ្ងៃទី០៣-១២-២០០៤ ខ្លួនសំណូមពរឱ្យជនល្មើសសងម៉ូតូខ្លួនតម្លៃ១៧៥០ដុល្លា និង ទាមទារជម្ងឺចិត្ត ១០០០ដុល្លា ។

-តាមចម្លើយចុះថ្ងៃទី១៥-០២-២០០៥ របស់ឈ្មោះ [redacted]សា.[redacted] **អឿង** ជាសាក្សីឆ្លើយនៅប៉ូលីសប្រហាក់ប្រហែលគ្នាថាៈ នៅវេលាម៉ោង ២១:៣០នាទី ថ្ងៃទី១៥-០២-២០០៥ ខ្លួនជិះម៉ូតូជាមួយជនរងគ្រោះជាមួយមិត្តភ័ក្ត្រ

តាមផ្លូវ១០៩ រួចបត់ចូលផ្លូវ១៦៦ ឈប់នៅមុខផ្ទះលេខ២៧E₀ ផ្លូវខឿងហែម ។ ពេលចុះពីលើម៉ូតូមានជនល្មើសម្នាក់ដើរមករកពួកខ្លួនដោយនៅដៃមានកាំភ្លើង បានគំរាមថា កុំស្រែកប្រយ័ត្នបាញ់ចោល ពេលនោះខ្លួន និងពួកម៉ាកម្នាក់ទៀតរត់ពួនច្រកខឿងហែម មួយស្របក់ចេញមក ស្រាប់តែជនល្មើសយកម៉ូតូជនរងគ្រោះជិះចេញបាត់ទៅ ទើបខ្លួនរត់មកប្តឹងសមត្ថកិច្ច ។ ភិនភាគជនល្មើសមាឌធំល្មម ខ្មៅស្រអែម កំពស់ប្រហែល១ម៧០ ពាក់អាវយឺតដៃវែងបង្ហង់ៗពណ៌ខៀវ+ ស ។

-តាមចម្លើយចុះថ្ងៃទី១៧-០២-២០០៥ របស់ឈ្មោះ [redacted] គក់ ជាជនជាប់ចោទឆ្លើយនៅប៉ូលីសថា: កាលពីថ្ងៃទី១៦-០២-២០០៥ ម៉ោង៨យប់ ខ្លួនកំពុងនៅផ្ទះជាមួយឈ្មោះ [redacted] តឹក និង [redacted] គឿន ហើយបានបបួលគ្នាធ្វើសកម្មភាពប្លន់ ហើយក៏នាំគ្នាជិះម៉ូតូម៉ាកប៉េសពណ៌ស្វែជាមួយឈ្មោះ [redacted] តឹក ហើយឈ្មោះ [redacted] គឿន ជាអ្នកឌុបខ្លួនជិះកណ្តាល ហើយឈ្មោះ [redacted] តឹក សៀតកាំភ្លើងK៥៩នៅចង្កេះ ។ ជិះដើររកម៉ូតូដើម្បីប្លន់តាមផ្លូវស៊ីសុវត្ថិ លុះដល់ស្តូនសម្តេចជា ស៊ីម ក៏ត្រូវកម្លាំងចម្រុះសង្ស័យកំពុងត្រួតពិនិត្យជាតិផ្ទុះឱ្យឈប់ ពួកខ្លួនបត់ម៉ូតូមកក្រោយបានបន្តិចក៏ត្រូវសមត្ថកិច្ចឃាត់ឆែកឆេររកឃើញអាវុធK៥៩ ក៏ឃាត់ខ្លួនបញ្ជូនមកអធិការ ។ ថាខ្លួនធ្លាប់ប្លន់ម៉ូតូ៣លើកមកហើយៗប្លន់ម៉ូតូជនរងគ្រោះនេះជាលើកទី៣ នៅថ្ងៃទី១៥-០២-២០០៥ ម៉ោង២១:៣០នាទី ផ្លូវលេខ១៦៦ ក្រោយរោងកុនអង្គរ មានគ្នាពីរនាក់ ដោយឈ្មោះ [redacted] តឹក ជាអ្នកភ្ជង់គំរាម រួបខ្លួនបើកម៉ូតូ DH ពណ៌ក្រហម ។ ពេលប្លន់បានហើយ អាតឹក យកម៉ូតូទៅទុកនៅផ្ទះជួល លុះព្រឹកឡើងជិះយកទៅលក់ឱ្យលុយមកខ្លួន៤០ដុល្លា ។ ម៉ូតូដែលសមត្ថកិច្ចដកយក គឺម៉ូតូម៉ាកC១០០កូរ៉េ ជារបស់ខ្លួន, ម៉ូតូDH៨៨ ពណ៌ក្រហមជារបស់ឈ្មោះ [redacted] គឿន, ម៉ូតូម៉ាកប៉េស ពណ៌ស្វែរបស់ឈ្មោះ [redacted] តឹក ។

-តាមចម្លើយចុះថ្ងៃទី២១-០២-២០០៥ របស់ឈ្មោះ [redacted] គក់ ជាជនជាប់ចោទឆ្លើយនៅអយ្យការ, ថ្ងៃទី២២-០២-២០០៥ នៅចៅក្រមស៊ើប ប្រហាក់ប្រហែលគ្នាថា: នៅថ្ងៃទី១៥-០២-២០០៥ ខ្លួននឹង [redacted] តឹក ពិតជាបានធ្វើសកម្មភាពប្លន់ម៉ូតូនៅក្រោយម៉ុំរោងកុនអង្គរ បានម៉ូតូC៩០ ចង្កៀងជ្រុង ពណ៌ទឹកប្រាក់ ស្អែកឡើងថ្ងៃទី១៦ ឈ្មោះ តឹក យកម៉ូតូនោះទៅលក់មិនដឹងបានលុយប៉ុន្មានទេ ឱ្យខ្លួនបាន៤០$ ។ មធ្យោបាយធ្វើសកម្មភាពមានអាវុធខ្លី K៥៩មួយដើម ជិះម៉ូតូDH៨៨ ឌុបឈ្មោះ តឹកៗជាអ្នកភ្ជង់ជនរងគ្រោះ និង ជិះម៉ូតូជនរងគ្រោះ ។ ខ្លួនពុំស្គាល់ឈ្មោះ [redacted] ខ្លី ទេ ហើយពុំដែលយកម៉ូតូលក់ដែរ ។ បញ្ជាក់ថា កាំភ្លើងពុំមែនជារបស់ខ្លួនទេ ជារបស់ឈ្មោះ [redacted] តឹក មានយូរមកហើយ ព្រោះថាធ្លាប់ធ្វើអង្គរក្សសម្តេច ហ៊ុន សែន ។

-តាមចម្លើយរបស់ឈ្មោះ [redacted] គក់ ជាជនជាប់ចោទ ឆ្លើយនាពេលសវនាការតុលាការថ្នាក់ក្រោមថា: ខ្លួនពុំបានប្លន់នៅពេលសមត្ថកិច្ចចាប់ខ្លួនទេ គឺឃាត់ខ្លួនៗនៅពេលឆែកអាវុធតាមផ្លូវជាមួយឈ្មោះ [redacted] តឹក ហើយឆែកឃើញអាវុធខ្លីមួយដើមពីឈ្មោះ [redacted] តឹក ។ ពេលប្លន់ម៉ូតូពណ៌ទឹកប្រាក់នៅម៉ុំក្រោយរោងកុនអង្គរ ក្នុងសង្កាត់អូរឫស្សី មានគ្នាពីរនាក់ បានជិះម៉ូតូខ្លួនទៅឃើញម៉ូតូមួយគ្រឿងជិះគ្នាបីនាក់ ឈ្មោះ [redacted] តឹក ចុះភ្ជង់គំរាមយកជិះតែម្តង ។ ខ្លួនត្រូវសមត្ថកិច្ចវាយឆ្លើយដូច [redacted] តឹក ដែរ តាមពិតពេលចាប់ខ្លួនៗពុំបានប្លន់ទេ ។ សំណូមពរតុលាការមេត្តាបន្ធូរបន្ថយទោសដល់ខ្លួន ៗ

-តាមចម្លើយចុះថ្ងៃទី១៨-០២-២០០៥ របស់ឈ្មោះ [redacted] តឹក ជាជនជាប់ចោទឆ្លើយនៅប៉ូលីសប្រហាក់ប្រហែលចម្លើយ [redacted] គក់ ដែរថាៈ ខ្លួនធ្លាប់ធ្វើសកម្មភាពប្លន់ម៉ូតូចំនួន៥លើក បានសំរេច៤លើក ការប្លន់ម៉ូតូC៩០ ពណ៌ទឹកប្រាក់ នៅថ្ងៃទី១៥-០២-២០០៥ ម៉ោង២១ៈ៣០នាទី នៅចំណុចផ្លូវ១៦៦ ជាលើកទី៣ បានប្រើអាវុធK៥៩ ខ្លួនជាអ្នកភ្ជង់ជនរងគ្រោះដែលជិះគ្នា៣នាក់ ប្រុស១ស្រី២នាក់ ។ ពេលប្លន់បានខ្លួនជាអ្នកជិះម៉ូតូជនរងគ្រោះ ទៅទុកនៅផ្ទះជួល ហើយព្រឹកឡើងខ្លួនជិះម៉ូតូទៅលក់ឱ្យឈ្មោះ ខ្លី បានលុយចំនួន៥៧០$ ។ មធ្យោបាយប្លន់ជិះម៉ូតូ DH ពណ៌ក្រហម ជាម៉ូតូ[redacted]គៀន ។ ចំពោះអាវុធK៥៩ ខ្លួនទិញពីឈ្មោះ [redacted] វណ្ណៈ ក្នុងតម្លៃ៨០$ រយៈពេល៦ខែហើយ ឯម៉ូតូC១២៥ ពណ៌ខៀវ ខ្លួនទិញនៅគីរីរម្យតម្លៃ៩៩០$ សំរាប់ជិះប្លន់ ហើយបានលក់រយៈពេលមួយខែហើយៗមកទិញម៉ូតូម៉ាកប៉េស តម្លៃ២៤០$ ។ ចំពោះគ្រឿងបន្លាស់ម៉ូតូនៅក្នុងផ្ទះជួល ជារបស់ឈ្មោះ [redacted] គក់ ប្លន់រួចដោះទុកក្នុងផ្ទះជួល ។

-តាមចម្លើយរបស់ឈ្មោះ [redacted] តឹក ជាជនជាប់ចោទឆ្លើយនៅអយ្យការ, ចៅក្រមស៊ើប និង ពេលសវនាការថាៈ នៅថ្ងៃទី១៥-០២-២០០៥ ខ្លួននឹង [redacted] គក់ ហៅ នែម ពិតជាបានធ្វើសកម្មភាពប្លន់ម៉ូតូ ប្រាកដមែន ប្លន់នៅក្រោយម៉ុំរោងកុនអង្គរ បានម៉ូតូហុងដាគុបC៩០ ចង្កៀងជ្រុង ពណ៌ទឹកប្រាក់ មធ្យោបាយប្លន់មានអាវុធខ្លីK៥៩ និង ម៉ូតូ DH ៨៨ ស្អែកឡើងថ្ងៃទី១៦-០២-២០០៥ ខ្លួនយកទៅលក់ឱ្យឈ្មោះ [redacted] ខ្លី បានតម្លៃ៥៥៥$ ខ្លួននឹងឈ្មោះ [redacted] គក់ ពុំដែលបានស្គាល់រាប់អានឈ្មោះ [redacted] ខ្លី ទេ ពេលស្គាល់ៗនៅពេលយកម៉ូតូទៅលក់ ហើយបានសុំលេខទូរស័ព្ទគាត់ ឈ្មោះ [redacted] ខ្លី ពុំដឹងថាម៉ូតូដែលគាត់ទិញខ្លួន ជាម៉ូតូខ្លួនប្លន់ទេ ហើយខ្លួនលក់ឱ្យគាត់ គឺតាមតម្លៃទីផ្សារ ។ អាវុធK៥៩ ជារបស់ខ្លួនពុំមានលិខិតអនុញ្ញាតឱ្យប្រើប្រាស់ទេ ។

-តាមចម្លើយរបស់ឈ្មោះ [redacted] ខ្លី ជាជនជាប់ចោទឆ្លើយនៅប៉ូលីស, អយ្យការ និង ចៅក្រមស៊ើបថាៈ ខ្លួនបានទិញម៉ូតូពីឈ្មោះ [redacted] តឹក ជាចោរប្លន់ចំនួនពីរគ្រឿង គឺលើកទី១ថ្ងៃទី០៣-០២-២០០៥ ម៉ោង៩ព្រឹក ម៉ូតូគុបជ្រុង៩០ ពណ៌ស្វៃ ទិញតាមទូរស័ព្ទនៅចំណុចផ្សារដើមថ្កូវ តម្លៃ៣៥០$ ហើយខ្លួនបានលក់ឱ្យអ្នកទិញជិះមិនស្គាល់ឈ្មោះ នៅខេត្តស្វាយរៀង ។ លើកទី២ថ្ងៃទី១៦-០២-២០០៥ ម៉ោង៩ព្រឹក ទិញម៉ូតូ(កើតហេតុ)នេះហើយទៅយកនៅរង្វង់មូលផ្សារដើមថ្កូវតម្លៃ៥៧០$ ហើយម៉ូតូនេះបានលក់ទៅឱ្យឈ្មោះ ទី នៅស្រុកសំរោង ខេត្តតាកែវ បាន៦២០$ ដោយទូរស័ព្ទឱ្យមកយកនៅរង្វង់មូលក្បាលថ្នល់ តាមទូរស័ព្ទលេខៈ០១២ ៩៦៦ ០៨១ ខ្លួនស្គាល់ឈ្មោះ ទី នៅកន្លែងគូកជេរម៉ូតូ ។ ខ្លួនស្គាល់ឈ្មោះ [redacted] តឹក ថាជាមុខសញ្ញាចោរប្លន់ ហើយនៅថ្ងៃទី១៧-០២-២០០៥ វាទូរស័ព្ទហៅខ្លួនទិញម៉ូតូរបស់វាដែលប្លន់បាន ណាត់យកម៉ូតូនៅរង្វង់មូលផ្សារដើមថ្កូវ ស្រាប់តែសមត្ថកិច្ចឃាត់ខ្លួនៗតែម្តង ។

បានឃើញសាលក្រមព្រហ្មទណ្ឌលេខៈ៧៩(គ) ចុះថ្ងៃទី២៨-៦-២០០៥ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារ នៃសេចក្តីសំរេចដូចតទៅ :

១-ផ្តន្ទាទោសឈ្មោះ [redacted] គក់ ហៅ នែម ភេទប្រុស អាយុ២៣ឆ្នាំ និង ឈ្មោះ [redacted] តឹក ភេទប្រុស អាយុ២១ឆ្នាំ ដាក់ពន្ធនាគារកំណត់ចំនួន៧ឆ្នាំ(ប្រាំពីរឆ្នាំ) គិតចាប់ពីថ្ងៃឃុំខ្លួនថ្ងៃទី២២-០២-២០០៥ ពីបទៈ ប្លន់ និង ប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី១៥-០២-២០០៥ តាមមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និង មាត្រា៥៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។/.

២៦៥

២-ផ្តន្ទាទោសឈ្មោះ [redacted] ខ្លី ភេទប្រុស អាយុ២២ឆ្នាំ ដាក់ពន្ធនាគារចំនួន៣ឆ្នាំ(បីឆ្នាំ) តែទោសនេះត្រូវព្យួរសាកល្បងរយៈពេល៥ឆ្នាំ គិតចាប់តាំងពីថ្ងៃនេះតទៅ ពីបទៈទទួលផលចោរកម្ម ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី១៦-០២-២០០៥ តាមមាត្រា៥១ និង ៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៣-បង្គាប់ឱ្យឈ្មោះ [redacted] គត់ ហៅ [redacted]. [redacted] តឹក និងឈ្មោះ [redacted] ខ្លី រួមគ្នាសងសំណងម៉ូតូមួយគ្រឿងម៉ាកឌុបC៩០ ពណ៌ទឹកប្រាក់ស៊េរី២០០៤ តម្លៃ១៧៥០ដុល្លាអាមេរិក(មួយពាន់ប្រាំពីររយហាសិបដុល្លាអាមេរិក) និង ជម្ងឺចិត្តចំនួន៥០០$(ប្រាំរយដុល្លាអាមេរិក) ឱ្យទៅឈ្មោះ [redacted] គង់ ម្ចាស់ដើមបណ្តឹងវិញ ហើយសំណងជម្ងឺចិត្តលើសពីនេះត្រូវបដិសេធចោល ។

-ករណីរឹងទទឹងមិនព្រមសង ត្រូវដាក់គុកបង្ខំលើរូបកាយលើឈ្មោះ [redacted] គត់ ហៅ [redacted]. [redacted] តឹក. និងឈ្មោះ [redacted] ខ្លី និង រឹបអូសទ្រព្យសម្បត្តិផ្សេងៗរបស់ឈ្មោះ [redacted] គត់ ហៅ នែប. [redacted] តឹក. និងឈ្មោះ [redacted] ខ្លី លក់ឡាយឡុងដើម្បីជានាសំណង ដោយអនុវត្តតាមនីតិវិធី ដែលមានចែងក្នុងច្បាប់ស្តីពីការដាក់គុកបង្ខំដល់រូបកាយក្នុងរឿងព្រហ្មទណ្ឌ ។

៤-វត្ថុតាងមានម៉ូតូចំនួន៣គ្រឿងៈ

-ម៉ូតូម៉ាកC១០០កូរ៉េ ពណ៌ក្រហម គ្មានផ្លាកលេខ លេខម៉ាស៊ីន១៤៥២១០៦៥ លេខតួ១៦៨៤៥០១

-ម៉ូតូម៉ាកប៉េស ពណ៌ស្វៃ គ្មានផ្លាកលេខ លេខតួ និង លេខម៉ាស៊ីនTH១០៦៦១១

-ម៉ូតូម៉ាកDH៨៨ ពណ៌ក្រហម ផ្លាកលេខរលប់ លេខម៉ាស៊ីន៨៨E-១១៩១០២៩ លេខតួ១៩០៩៤៥ និង ក្បាំងម៉ូតូចំនួន២(ពីរ) កូនសោរមួយចំនួន ខ្មៅម៉ូតូមួយចំនួន និង ទូរស័ព្ទមួយគ្រឿងម៉ាកណូគា និង ប្រាក់ ២០$US(ម្ភៃដុល្លាអាមេរិក) ត្រូវរឹបអូសលក់ឡាយឡុងធានាសំណង ។

៥-ផ្លាកលេខម៉ូតូលេខៈ៨៣៣៦០ភ៣១ ត្រូវរឹបអូសប្រគល់ឱ្យម្ចាស់ដើមវិញ ។

៦-អាវុធខ្លីមួយដើមម៉ាកK៥៩ រលប់លេខ បង់មួយគ្រាប់ចំនួន២(ពីរគ្រាប់) និង ស៊ីមលេខ០១២ ៦៤៤ ០៦៨ ត្រូវរឹបអូស និង បំផ្លាញចោល ។

៧-សាលក្រមនេះជំនុំជម្រះ និង ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] គត់ ហៅ នែប និងឈ្មោះ [redacted] តឹក កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ខ្លី និង ដើមបណ្តឹងរដ្ឋប្បវេណី សំរេចបើកផ្លូវប្តឹងទាស់ និង ឧទ្ធរណ៍ ក្នុងកំណត់ច្បាប់ ។

-បានឃើញរបាយការណ៍ ចុះថ្ងៃទី០៣-០១-២០០៧ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ។

-បានឃើញសេចក្តីសន្និដ្ឋាន ចុះថ្ងៃទី១៧-០៣-២០០៦ របស់ព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ។

**នាពេលសវនាការ**

-ក្រឡាបញ្ជីអានចម្លើយជនជាប់ចោទឈ្មោះ [redacted] តឹក

-ក្រឡាបញ្ជីអានចម្លើយដើមបណ្តឹងឈ្មោះ [redacted] គង់

-ជនជាប់ឈ្មោះ [redacted] គត់ ឆ្លើយថាៈ ខ្លួនប្តឹងឧទ្ធរណ៍សុំឱ្យសាលាឧទ្ធរណ៍ ជួយបន្ធូរបន្ថយទោស ខ្លួនទទួលស្គាល់ការប្រព្រឹត្តរបស់ខ្លួន ដូចដែលលោកប្រធានបានសង្ខេបរឿងក្តីនេះ ។

-តំណាងមហាអយ្យការសន្និដ្ឋានថាៈ ជនជាប់ចោទបានឆ្លើយសារភាពទទួលកំហុស ហើយការផ្តន្ទាទោសរបស់សាលាដំបូងក្រុងភ្នំពេញ ឃើញថាត្រឹមត្រូវហើយ សុំឱ្យតម្កល់សាលក្រមដដែល ។

-មេធាវី [redacted] **យ៉ាវ៉ាន់** ការពារជនជាប់ចោទសន្និដ្ឋានថាៈ កូនក្តីខ្លួនបានឆ្លើយសារភាពទទួលកំហុសហើយ តែសុំឱ្យសាលាឧទ្ធរណ៍ពិចារណាដោយកូនក្តីខ្លួនក្រីក្រ ខ្វះការអប់រំ ឪពុកម្តាយក្រីក្រ ចាស់ជរា ចង់ឃើញកូនចៅបាននៅថែរក្សាឪពុកម្តាយវិញ ហេតុនេះសុំឱ្យសាលាឧទ្ធរណ៍ បន្ធូរបន្ថយទោសដល់កូនក្តីខ្លួន តាមសំណូមពរ ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹង

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានពិនិត្យគ្រប់ឯកសារ

-ក្រោយពីបានពិចារណាត្រឹមត្រូវហើយ

## សាលាឧទ្ធរណ៍

១-យល់ឃើញថាៈ ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៨-៦-២០០៥ របស់ឈ្មោះ [redacted] **គីក** និង [redacted] **គក់** ធ្វើឡើងតាមកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន យោងតាមបញ្ញត្តិមាត្រា១៧៨ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ និង មាត្រា៦០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-យល់ឃើញថាៈ ពាក្យសុំទទួលស្គាល់មេធាវី ចុះថ្ងៃទី០៧-០៣-២០០៦ សុំទទួលស្គាល់លោកមេធាវី [redacted] **យ៉ាវ៉ាន់** ជាមេធាវីរបស់ឈ្មោះ [redacted] **គីក** និង [redacted] **គក់** ធ្វើឡើងមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

៣-យល់ឃើញថាៈ តាមចម្លើយបំភ្លឺរបស់សាក្សី និង ចម្លើយបំភ្លឺរបស់ជនរងគ្រោះ និង តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **គីក** និង [redacted] **គក់** ផ្ទាល់បានបញ្ជាក់ឱ្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] **គីក** និង [redacted] **គក់** ពិតជាបានប្លន់ម៉ូតូរបស់ជនរងគ្រោះឈ្មោះ [redacted] **គចំ** ប្រាកដមែន *កាលពីថ្ងៃទី១៥-០២-២០០៥ ហើយ* ក្នុងការប្រព្រឹត្តអំពើប្លន់នេះ ជនជាប់ចោទបានប្រើប្រាស់នូវអាវុធ ដែលពុំមានច្បាប់អនុញ្ញាតទៀតផង ។

៤-យល់ឃើញថាៈ មានភស្តុតាង និង ពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] **គីក** និង [redacted] **គក់** ពីបទៈប្លន់ និង ប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី១៥-០២-២០០៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និង តាមមាត្រា៥៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៥-យល់ឃើញថាៈ រឿងក្តីនេះតុលាការក្រុងភ្នំពេញ បានធ្វើការអង្កេត និង លើកយកភស្តុតាងមកសំអាងជូនសព្វគ្រប់ហើយ សាលាឧទ្ធរណ៍ឯកភាពលើសំអាងហេតុនេះ ដូចនេះសាលាឧទ្ធរណ៍ ពុំចាំបាច់លើកយកសំអាងហេតុដដែលនេះ មកបញ្ជាក់ជាថ្មីទៀតទេ ។

៦-យល់ឃើញថាៈ ជនជាប់ចោទជាមនុស្សដែលស្ថិតនៅក្នុងវ័យក្មេង ខ្វះការពិចារណានូវទង្វើរបស់ខ្លួន ហើយក្រោយពីបានប្រព្រឹត្តអំពើរបស់ខ្លួនរួចមក ជនជាប់ចោទបានសារភាពនូវទោសកំហុសរបស់ខ្លួន ។ ម្យ៉ាងទៀត ជនជាប់...

២៦៧

ចោទទើបតែប្រព្រឹត្តអំពើល្មើសជាលើកទីមួយ ដែលគប្បីតុលាការពិចារណាអំពីកិរិតនៃការផ្តន្ទាទោស លើជនជាប់ចោទឱ្យបានសមរម្យ ។

៧-យល់ឃើញថា: សាលក្រមព្រហ្មទណ្ឌលេខ:៧៩(គ), ចុះថ្ងៃទី២៨-៦-២០០៥ របស់តុលាការក្រុងភ្នំពេញ ដែលសម្រេចសេចក្តីមកនេះ មានលក្ខណ:ត្រឹមត្រូវហើយ គប្បីតម្កល់ទុកជាបានការដដែល ។

## ហេតុដូច្នេះវិនិច្ឆ័យសេចក្តី

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៨-៦-២០០៥ របស់ឈ្មោះ [redacted] **តឹក** និង [redacted] **គត់** ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោល ដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ:៧៩(គ) ចុះថ្ងៃទី២៨-៦-២០០៥ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការដដែល ដោយគ្រាន់តែកែប្រែរយ:ពេល នៃការផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] **គត់** ហៅ **ឆែប** និង [redacted] **តឹក** ក្នុងចំណុចទី១ នៃសេចក្តីសម្រេចពីរយ:ពេល០៧(ប្រាំពីរ)ឆ្នាំ មករយ:ពេល០៥(ប្រាំ)ឆ្នាំ វិញ ។ ចំណុចក្រៅពីនេះ រក្សាទុកជាបានការដដែល ។

៣-សំរេចឃុំខ្លួនឈ្មោះ [redacted] **គត់** ហៅ **ឆែប** និង [redacted] **តឹក** នេះជាបន្ត ។

៤-សាលដីកានេះជំនុំជម្រះ និង ប្រកាសជាសាធារណ: ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **គត់** ហៅ **ឆែប** និង មេធាវីការពារ, កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] **តឹក** និង ដើមបណ្តឹង បើកផ្លូវប្តឹងតវ៉ា តាមកំណត់ច្បាប់ ។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និង កងកំលាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះឱ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា [redacted] |

ច្បាប់ចំលងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ,ថ្ងៃទី 14 ខែ 11 ឆ្នាំ២០១៤

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ប្រធានសាលាឧទ្ធរណ៍**

[redacted]

៤៦៨